ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
លេខ:...៤១០.......សសរ

រាជធានីភ្នំពេញ ថ្ងៃទី..០៤.... ខែ តុលា ឆ្នាំ ២០១២

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីចុះពិនិត្យគុណភាពនៃការសាងសង់ផ្ទះឈើនាឆ្នាំ ២០១១ ក្នុងកម្មវិធីសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជា ប្រធានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- យោងអនុក្រឹត្យលេខ ១៥៥៦ អនក្រ.តត ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៩ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ
- បានឃើញសេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាលេខ ៤២ សជណ.ចក ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៩ ស្តីពីគោលនយោបាយផ្តល់សម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ
- លិខិតលេខ ១៣៩៧ សជណ.ឧស ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការរៀបចំធ្វើការបែងចែកសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ ព្រមទាំងសម្រាប់ប្រជាពលរដ្ឋទូទៅដោយអនុលោមទៅតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១
- សេចក្តីសម្រេចលេខ ០២៧ ជនស/គសសជ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១១ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការបង្កើតគណៈកម្មការអនុវត្តសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ
- សេចក្តីសម្រេចលេខ ០៩៥ សសរ ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១១ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការបង្កើតគណៈកម្មការអនុវត្តនីតិវិធីលទ្ធកម្មរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីធ្វើការចរចាថ្លៃ និងចុះកិច្ចសន្យាផ្ទាល់ជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តគោលដៅចំនួន ១៦ ក្នុងការអភិវឌ្ឍទីតាំងសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ

- លិខិតលេខ ៦១៣៣ សហវ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការចាត់មន្ត្រី ១រូប របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីចូលរួមជាមួយក្រុមការងារចុះពិនិត្យគុណភាពផ្ទះឈើដែលបានសាងសង់នាឆ្នាំ ២០១១ ក្នុងទីតាំងសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ
- យោងតាមតម្រូវការចាំបាច់

## **សម្រេច**

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួងដើម្បីចុះពិនិត្យគុណភាពនៃការសាងសង់ផ្ទះឈើឆ្នាំ ២០១១ ក្នុងទីតាំងសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១) ឯកឧត្តមបណ្ឌិត **ឌុច វនទីត្ត** | អគ្គនាយករៀបចំដែនដី និងនគរូបនីយកម្ម និងជាអគ្គលេខាធិការ អ.គសសជ | ប្រធាន |
| ២) លោក **ឡុញ ប៉ុណ្ណាវ៉ា** | អគ្គាធិការរង នៃអគ្គាធិការដ្ឋាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៣) លោក **សរ សាមេធា** | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ៤) លោក **ប៉ែន ច័ន្ទសុខខេមរ៉ា** | អធិការ នៃអធិការដ្ឋាន | សមាជិក |
| ៥) លោក **សយ យោសាកា** | ប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញកិច្ច | សមាជិក |
| ៦) អភិបាលនៃគណៈអភិបាលខេត្តពាក់ព័ន្ធ | | សមាជិក |
| ៧) ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តគោលដៅ | | សមាជិក |

**ប្រការ ២.-**

ក្រុមការងារនេះមានភារកិច្ច ៖

- ចុះពិនិត្យ និងវាយតម្លៃគុណភាពស្របតាមកិច្ចសន្យាលើការសាងសង់ផ្ទះឈើក្នុងកម្មវិធីសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារឆ្នាំ ២០១១ នៅទីតាំងខេត្តក្រចេះ កំពង់ស្ពឺ កំពត កំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង។
- ធ្វើរបាយការណ៍ លើកយោបល់ និងវិធានការដោះស្រាយជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- អនុវត្តកិច្ចការផ្សេងៗទៀតដែលឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ប្រគល់ជូន។

**ប្រការ ៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តគោលដៅ ឯកឧត្តម អស់លោក ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ទេសរដ្ឋមន្ត្រី**

អ៊ឹម ឈុនលឹម

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច តេជោ នាយករដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-អង្គភាពប្រឆាំងអំពើពុករលួយ
-រដ្ឋបាលខេត្តគោលដៅ
-ដូចប្រការ ៣
-ឯកសារ-កាលប្បវត្តិ